# សៀវភៅណែនាំ
# ស្តីអំពី
# ការរៀបចំគម្រោងអាកាសធាតុវៃឆ្លាត



# សៀវភៅណែនាំស្តីពី ការរៀបចំគម្រោងអាកាសធាតុវៃឆ្លាត






## សៀវភៅណែនាំសម្រាប់អ្នកសម្របសម្រួល

សមាគមធាងត្នោត
Sahmakum Teang Tnaut- a Cambodian Urban NGO

MISEREOR

រក្សាសិទ្ធគ្រប់យ៉ាង ដោយ អង្គការសមាគមធាងត្នោត ២០១៨

សៀវភៅណែនាំស្តីពី ការរៀបចំគម្រោងអាកាសធាតុវៃឆ្លាត - សៀវភៅសម្រាប់អ្នកសម្របសម្រួល

យើងលើកទឹកឲ្យធ្វើការថតចម្លង ផលិតឡើងវិញ ឬក៏យកលំនាំតាមនូវផ្នែកខ្លះឬផ្នែកទាំងអស់នៃសៀវភៅនេះដើម្បីបំពេញតម្រូវការមូលដ្ឋាន ចំពោះផ្នែកដែលអ្នកបានយកពីសៀវភៅនេះទៅប្រើប្រាស់ឬដាក់ចូលក្នុងសៀវភៅរបស់ខ្លួនដើម្បីប្រើប្រាស់ អ្នកត្រូវតែដាក់សេចក្តីយោងទៅនឹងសៀវភៅច្បាប់ដើមឬយោងការបោះពុម្ពច្បាប់ដើម ហើយត្រូវចែកចាយក្នុងគោលបំណងមិនស្វែងរកប្រាក់ចំណេញ។ អង្គការឬបុគ្គលណាក៏ដោយ ដែលចង់ធ្វើការថតចំលងផលិតឡើងវិញ ឬយកលំនាំតាមនូវផ្នែកណាមួយឬផ្នែកទាំងអស់នៃសៀវភៅនេះក្នុងគោលបំណងធ្វើពាណិជកម្ម ត្រូវតែទទួលការអនុញ្ញាតពីអ្នកផលិត និងអ្នកសសេរជាមុនសិន។

មុនពេលចាប់ផ្តើមធ្វើការបកប្រែ ឬការយកលំនាំតាមសៀវភៅនេះ ឬខ្លឹមសាររបស់វាសូមធ្វើការទាក់ទងអ្នកសរសេរសៀវភៅនេះ ដើម្បីស្នើសុំយោបល់ដើម្បីធ្វើបច្ចុប្បន្នភាពនូវ ព័ត៌មានដែលមានក្នុងសៀវភៅនេះ ហើយដើម្បីជៀសវាងនូវការធ្វើសកម្មភាពជាន់គ្នា។ សូមធ្វើឱ្យអ្នកសរសេរនូវឯកសារថតចំលងខ្លះ ដែលក្នុងនោះមានដូចជាអត្ថបទដែលយកចេញពីសៀវភៅដែលបានប្រើប្រាស់។

អង្គការសមាគមធាងត្នោត

ផ្ទះលេខ៧ ផ្លូវ៤៩៤ សង្កាត់ផ្សារដើមថ្កូវ

ខណ្ឌចំការមន រាជធានីភ្នំពេញ

អ៊ីម៉ែល: info@teangtnaut.org

គេហទំព័រ:www. teangtnaut.org

**ឧបត្ថម្ភដោយ៖**

MISEREOR

# អារម្ភកថា

ការប្រែប្រួលអាកាសធាតុ បានកំពុងក្លាយជាបញ្ហាប្រឈមចម្បង និងជះឥទ្ធិពលធ្ងន់ធ្ងរដល់កំណើនសេដ្ឋកិច្ច និងការអភិវឌ្ឍប្រកបដោយចីរភាព ដែលយើងទាំងអស់គ្នាត្រូវចាត់វិធានការឆ្លើយតបឱ្យបានទាន់ពេលវេលា។ ក្នុងន័យនេះការបញ្ជ្រាបចំណេះដឹង ស្តីពីការប្រែប្រួលអាកាសធាតុក្នុងវិស័យអប់រំលើសមត្ថភាពមនុស្ស គឺជាវិធានការចម្បងមួយស្របតាម ផែនការយុទ្ធសាស្ត្រឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុជាសកល។

ការស្វែងយល់ពីការប្រែប្រួលអាកាសធាតុ ផលប៉ះពាល់ គោលនយោបាយ និងក្របខណ្ឌការងារផ្លូវច្បាប់ (ជាតិ និង អន្តរជាតិ) រួមបញ្ចូលទាំងយន្តការហិរញ្ញវត្ថុអាកាសធាតុ អ្វីជាគម្រោងវៃឆ្លាតឆ្លើយតប នឹងការប្រែប្រួលអាកាសធាតុ? គំនិតនៃការសម្របខ្លួន និងការកាត់បន្ថយយុទ្ធសាស្ត្រនិងការជ្រោមជ្រែង ក្នុងគម្រោងវៃឆ្លាតឆ្លើយតប នឹងការប្រែប្រួលអាកាសធាតុវិធានការចំណាយតិចនិងមិនចំណាយរបៀបជួយសហគមន៍ក្រីក្រនៅទីក្រុង។

# បញ្ជីខ្លាតអក្សរកាត់ និងអត្ថន័យ

| អក្សរកាត់ | ពាក្យពេញ |
|---|---|
| **STT** | Sahmakum Teang Tnaut |
| **3R** | Reduce, Reuse and Recycle |
| **LED** | Light-emitting diode |
| **CFL** | Compact fluorescent lamp |
| **CFCs** | Chlorofluorocarbons |
| **EDC** | Electricity Du Cambodge |
| **C02** | Carbon dioxide |
| **C3** | Ozone |
| **GHG** | Greenhouse Gas |
| **H20** | Hydrogen |
| **%** | Percentage |
| **CH4** | Methana |

# មាតិកា


១. សេចក្តីផ្តើម....................................................................................................១

១.១. គោលបំណង..................................................................................................១

១.២. ក្រុមគោលដៅ................................................................................................១

១.៣. ទិដ្ឋភាពទូទៅ...............................................................................................២

១.៤. វិធីសាស្រ្ត .......................................................................................................៤

២. មេរៀនលំអិត......................................................................................................៥

២.១. ទិដ្ឋភាពទូទៅ នៃវគ្គបណ្តុះបណ្តាល...................................................................៥

២.១.១. ការណែនាំខ្លួន...............................................................................................៥

២.១.២. ការណែនាំវគ្គបណ្តុះបណ្តាល............................................................................៦

មេរៀនទី១៖ ការណែនាំអំពីគម្រោងអាកាសធាតុវៃឆ្លាតសម្រាប់សហគមន៍ក្រីក្រក្នុងទីក្រុង....................៧

មេរៀនទី២៖ការសង់លំនៅឋានដែលងាយសម្របខ្លួនទៅនឹងអាកាសធាតុក្តៅសើម...........................១០

មេរៀនទី៣៖ កាត់បន្ថយការប្រើប្រាស់ថាមពល និង ថ្លៃចំណាយ..................................................១៣

មេរៀនទី៤៖ ការគ្រប់គ្រងកាកសំណល់រឹង ឬសំរាម និង ការបង្កើតតំបន់បៃតង................................១៧

មេរៀនទី៥៖ ទឹក និង បង្គន់អនាម័យ.....................................................................................១៩

មេរៀនទី៦៖ ការធ្វើផែនការ និង ការអនុវត្តការកែលម្អអាកាសធាតុវៃឆ្លាត.......................................២១

ករណីសិក្សាទី១.....................................................................................................២៤

ករណីសិក្សាទី២.....................................................................................................២៥

ករណីសិក្សាទី៣.....................................................................................................២៦

ករណីសិក្សាទី៤.....................................................................................................២៧

ករណីសិក្សាទី៥.....................................................................................................២៨

ឧបសម្ព័ន្ធ៖ រូបភាពសកម្មភាពនៃគម្រោង បម្រែបម្រួលអាកាសធាតុវៃឆ្លាត....................................២៩

ពាក្យពិបាក..........................................................................................................៣១

## ១. សេចក្តីផ្តើម

កំឡុងពេលជាង៣០ឆ្នាំ កន្លងមកនេះយើងឃើញថា មនុស្សលោកបានធ្វើនូវសកម្មភាពជាច្រើន ដែលធ្វើឱ្យប៉ះពាលដល់អាកាសធាតុ។ ១០០ឆ្នាំមុន សីតុណ្ហភាពបានកើនជាមធ្យម១អង្សាសេនៅលើ ភពផែនដី។ ចំនួន នេះវានឹងកើនឡើងរហូតដល់ទៅ៣អង្សាសេនៅឆ្នាំ២០៥០ ប្រសិនមនុស្សនៅតែបន្ត នូវសកម្មភាពដូចបច្ចុប្បន្ន។ ការកើនឡើងនៃសីតុណ្ហភាពនេះត្រូវបានគេឱ្យឈ្មោះថាសីតុណ្ហភាពនៅលើ ពិភពលោក(Global Warming) ឬ ការប្រែប្រួលអាកាសធាតុ (Climate Change)។ សកម្មភាពចម្បង ដែលនាំឱ្យមានការប្រែប្រួលអាកាសធាតុនោះ គឺបណ្តាលមកពីមានការកើនឡើងនៃការបំភាយឧស្ម័នផ្ទះ កញ្ចក់ (Greenhouse Gases) ដូចជាកាបូនឌីអុកស៊ីត ($CO_2$) មេតាន (Methane) និង ឧស្ម័នបំពុលខ្យល់ ផ្សេងៗទៀត។សកម្មភាពរបស់មនុស្ស ដូចជាការដុតប្រេងឥន្ទនៈ(Fossil Fuels) ធ្យូង ប្រេង និង ឧស្ម័នធម្មជាតិនានាដែលនាំឱ្យមានការកើនឡើងនៃកាបូន។ ជាក់ស្តែងការដុតប្រេងឥន្ទនៈ គឺដើម្បីទាញ យកជាថាមពលអគ្គិសនី។ ករណីជាច្រើនដែលនាំឱ្យមានការប្រែប្រួលអាកាសធាតុនោះគឺការបាត់បង់ ព្រៃឈើ ការបង្កើនសកម្មភាពកសិកម្ម និងសកម្មភាពផ្សេងៗទៀត។

## ១.២. គោលបំណង

គោលបំណងនៃវគ្គបណ្តុះបណ្តាលនេះគឺដើម្បីរៀបចំបុគ្គលិកអង្គការសមាគមធាងត្នោត(STT)និង អង្គការដៃគូដើម្បីអាចជួយផ្តល់ចំណេះដឹងដល់សហគមន៍ក្រីក្រក្នុងទីក្រុង ក្លាយជាគម្រោងវៃឆ្លាតឆ្លើយតប នឹងអាកាសធាតុ។ គម្រោងវៃឆ្លាតឆ្លើយតបនឹងការបំរែបំរួលអាកាសធាតុមានន័យថាជាការសម្របខ្លួនទៅ នឹងការប្រែប្រួលនៃអាកាសធាតុ និងការកាត់បន្ថយការបំរែបំរួលអាកាសធាតុជាមាគ៌ាឆ្ពោះទៅរកការ អភិវឌ្ឍកាបូនទាបដែលអាចសម្រេចជោគជ័យ។

## ១.៣. ក្រុមគោលដៅ

ក្រុមគោលដៅនៃការបណ្តុះបណ្តាលនេះគឺ បុគ្គលិក អង្គការសមាគមធាងត្នោត (STT) និងអង្គការ ដៃគូ ក៏ដូចជាដៃគូពាក់ព័ន្ធផ្សេងៗទៀតដែលធ្វើការជាមួយសហគមន៍ក្រីក្រនៅកម្ពុជា។

## ១.៣. ទិដ្ឋភាពទូទៅ

| ប្រធានបទ | មាតិកា |
|---|---|
| ទិដ្ឋភាពទូទៅនៃវគ្គបណ្តុះបណ្តាលពីគម្រោងអាកាសធាតុវៃឆ្លាត<br>រយៈពេល៖ ១០ នាទី | • ផ្តល់នូវទិដ្ឋភាពទូទៅអំពីវគ្គបណ្តុះបណ្តាល និងមេរៀន<br>• កាលវិភាគ |
| មេរៀនទី១៖<br>ការណែនាំស្តីពីគម្រោងអាកាសធាតុវៃឆ្លាតសម្រាប់សហគមន៍ក្រីក្រក្នុងទីក្រុង | • ការស្វែងយល់អំពី ការប្រែប្រួលអាកាសធាតុផលប៉ះពាល់ គោលនយោបាយនិងក្របខណ្ឌការងារផ្លូវច្បាប់ (ជាតិ និង អន្តរជាតិ) រួមបញ្ចូលទាំងយន្តការហិរញ្ញវត្ថុ អាកាសធាតុ<br>• តើអ្វីជាគម្រោងវៃឆ្លាត? ទស្សនៈនៃការសម្របខ្លួន និងការកាត់បន្ថយ<br>• យុទ្ធសាស្ត្រ និងការអន្តរាគមក្នុងគម្រោងអាកាសធាតុវៃឆ្លាត<br>• វិធានការចំណាយតិច និងមិនមានការចំណាយ<br>• វិធីសាស្ត្រជួយសហគមន៍ក្រីក្រនៅក្នុងទីក្រុង |
| មេរៀនទី២៖<br>គម្រោងសង់លំនៅឋានដែលងាយសម្របខ្លួនទៅនឹងអាកាសធាតុក្តៅសើម<br>រយៈពេល៖ ១ ម៉ោង | • ការវិភាគអាកាសធាតុ<br>• កត្តាអាកាសធាតុដែលពាក់ព័ន្ធ នឹងការរចនាលំនៅឋាន<br>• ផ្ទះបែបបុរាណ ជាគំរូ<br>• យុទ្ធសាស្ត្រ និងវិធានការ៖ ការណែនាំ ការស្រូបខ្យល់ចេញចូល ការធ្វើឱ្យមានម្លប់ ដំបូលប្រើប្រាស់អ៊ីស៊ូឡង់ និងការលាបដំបូល ឬជញ្ជាំងពណ៌ស |
| មេរៀនទី៣៖<br>កាត់បន្ថយការប្រើប្រាស់ថាមពលនិងថ្លៃចំណាយ<br>រយៈពេល៖៤៥ នាទី | • ថាមពល និងការបំភាយឧស្ម័នពុល<br>• កាត់បន្ថយការចំណាយលើថាមពល<br>• យុទ្ធសាស្ត្រ និងវិធានការ៖ អំពូលស្រូបពន្លឺព្រះអាទិត្យ ផលិតពីដប ប្រព័ន្ធបំភ្លឺពន្លឺព្រះអាទិត្យ (សូឡា) ការវិភាគតម្លៃការវិភាគលើការចម្អិនមានប្រសិទ្ធិភាព (ការប្រើប្រាស់ឧបករណ៍ ឬសម្ភារៈ) |

| | |
|---|---|
| មេរៀនទី៤៖<br>ការគ្រប់គ្រងកាកសំណល់រឹង-រាវ និងការបង្កើតតំបន់បៃតង<br><br>រយៈពេល៖ ១ ម៉ោង | • ស្ថានភាពបច្ចុប្បន្ន<br>• គំនិត ៣R (កាត់បន្ថយ ប្រើឡើងវិញ កែច្នៃឡើងវិញ)<br>• យុទ្ធសាស្ត្រ និងវិធានការ៖<br>ទិវាសំអាតសហគមន៍ ការញែកសំរាម កន្លែងប្រមូលសំរាម ការធ្វើជីកំប៉ុស សួនបន្លែ ឡជីវឧស្ម័ន ជញ្ជាំងដែលធ្វើពីដបប្លាស្ទិក |
| មេរៀនទី៥៖<br>ទឹកស្អាត និងបង្គន់អនាម័យ<br><br>រយៈពេល៖៤៥ នាទី | •ការទទួលបានការប្រើប្រាស់ទឹកស្អាត សុវត្ថិភាព និងបង្គន់អនាម័យ<br>• ស្ថានភាពបច្ចុប្បន្ន<br>• យុទ្ធសាស្ត្រ និងវិធានការ៖<br>ការប្រមូលទឹកភ្លៀង ធុងចំរោះទឹកសេរ៉ាមិច ការច្រោះទឹកស្អុយតាមធម្មជាតិការការពារទឹកជំនន់ |
| មេរៀនទី៦៖<br>ការធ្វើផែនការ និងការអនុវត្តគម្រោងអាកាសធាតុវៃឆ្លាត<br><br>រយៈពេល៖ ១ម៉ោង៣០នាទី | • តើមានវិធីសាស្ត្រដូចម្តេចដើម្បីឱ្យសហគមន៍បានយល់ដឹង?<br>• តើគួរបង្កើតផែនការអភិវឌ្ឍន៍គម្រោងអាកាសធាតុវៃឆ្លាតដែលសមស្របនឹងគ្រួសារក្រីក្រមានចំណូលមធ្យមដោយរបៀបណា?<br>• កញ្ចប់ថវិកា និង ផែនការសកម្មភាព? |

## ១.៤. វិធីសាស្ត្រ

វគ្គបណ្តុះបណ្តាលនេះ ប្រើប្រាស់នូវវិធីសាស្ត្របង្រៀនខុសៗពីគ្នាដើម្បីធានាបានថាអ្នកចូលរួមទទួលបានបទពិសោធន៍នៃការសិក្សាប្រកបដោយប្រសិទ្ធភាព និងអត្ថប្រយោជន៍។ វិធីសាស្ត្រនិងសម្ភារៈបង្រៀនមានខាងក្រោម៖

- ការធ្វើបទបង្ហាញជាមួយផ្ទាំងស្លាយ ផ្ទាំងក្រដាស់ធំ  និងរូបភាព
- ការបកស្រាយរបស់វាគ្មិន
- សំណួរ-ចំលើយ
- ឯកសារពាក់ព័ន្ធពីគម្រោងអាកាសធាតុវៃឆ្លាត
- ការធ្វើលំហាត់រៀងៗខ្លួន និងជាក្រុម
- ក្រុមពិភាក្សា
- របៀបសិក្សាតាមបែបដើរមើលតាមជញ្ជាំង (Gallery walk)
- ការបង្ហាញវីដេអូ
- ការវិភាគលើករណីសិក្សា
- សំណួរ-ចំលើយផ្ទាល់មាត់

# ២. មេរៀនលំអិតនៃវគ្គបណ្តុះបណ្តាល

## ២.១. ទិដ្ឋភាពទូទៅ នៃវគ្គបណ្តុះបណ្តាល

| មាតិកា៖ការណែនាំខ្លួនរបស់អ្នកបណ្តុះបណ្តាល និងអ្នកចូលរួម ទិដ្ឋភាពទូទៅនៃមេរៀនដែល ត្រូវបណ្តុះបណ្តាលការធ្វើបទបង្ហាញអំពីមាតិកា | | |
|---|---|---|
| **ដំណើរការ** | **គោលបំណង** | **រយៈពេល (គិតជានាទី)** |
| ការណែនាំខ្លួន | ការណែនាំខ្លួនរបស់អ្នកបណ្តុះបណ្តាល និងអ្នកចូលរួម និងការលើកឡើងពីការរំពឹងទុករបស់អ្នកចូលរួម | ៥ |

### ២.១.១. ការណែនាំខ្លួន

### គោលបំណង និង ទិសដៅ

- ការណែនាំខ្លួនរបស់អ្នកសម្របសម្រួល និងអ្នកចូលរួម
- ការលើកឡើងពីការរំពឹងទុករបស់អ្នកចូលរួម

### សម្ភារៈ

- ហ្វឺត និងក្រដាសទំហំ (ក្រដាស់ទំហំអេហ្វ A4) មួយសន្លឹកឱ្យអ្នកចូលរួម សម្រាប់ការណែនាំខ្លួន
- អ្នកសម្របសម្រួលត្រូវណែនាំខ្លួនអំពីឈ្មោះប្រទេស(ប្រសិនចាំបាច់)ប្រវត្តិការងារនិងបទពិសោធន៍
- អ្នកសម្របសម្រួលអញ្ជើញអ្នកចូលរួមឱ្យណែនាំខ្លួន ដោយចាប់ផ្តើមពីអ្នកដែលអាយុតិចជាងគេ
- ពួកគេត្រូវចាប់ផ្តើមប្រាប់ឈ្មោះខ្លួនឯង ដោយភ្ជាប់ជាមួយនូវគោលបំណង ហើយគោលបំណងនោះត្រូវមានតួអក្សរដូចឈ្មោះខ្លួនឯង (ប្រសិនបើអាច)។
- បន្ថែមពីលើនោះ ពួកគេត្រូវណែនាំឈ្មោះក្រុមហ៊ុន ឬអង្គការ និងតួនាទី ក៏ដូចជារៀបរាប់ពីការរំពឹងទុករបស់ពួកគេចំពោះវគ្គបណ្តុះបណ្តាល។
- ឈ្មោះដែលមានភ្ជាប់ជាមួយគោលបំណងនោះ ត្រូវសរសេរចូលទៅក្នុងកាតឈ្មោះ រួចដាក់នៅពីមុខអ្នកចូលរួមរៀងៗខ្លួន។

## ២.១.២. ការណែនាំវគ្គបណ្តុះបណ្តាល

### គោលបំណង និងទិសដៅ

- បង្ហាញទិដ្ឋភាពទូទៅនៃមេរៀនសម្រាប់វគ្គបណ្តុះបណ្តាលដើម្បីអោយអ្នកចូលរួមយល់អំពីអ្វីដែលពួកគាត់នឹងសិក្សាក្នុងកំឡុងពេលវគ្គបណ្តុះបណ្តាល។

### សម្ភារៈ

- ការធ្វើបទបង្ហាញ ដោយប្រើប្រាស់ផ្ទាំងស្លាយ
- ការធ្វើបទបង្ហាញអាចបត់បែនទៅតាមអ្នកចូលរួម
- ជាពិសេសត្រូវកំណត់ម៉ោង ដើម្បីអោយត្រូវជាមួយនឹងកាលវិភាគនៃវគ្គបណ្តុះបណ្តាល

# មេរៀនទី១
# ការណែនាំអំពីគម្រោងអាកាសធាតុវៃឆ្លាតសម្រាប់សហគមន៍ក្រីក្រក្នុងទីក្រុង

| |
|---|
| មាតិកា៖ ការស្វែងយល់អំពីប្រែប្រួលអាកាសធាតុ ផលប៉ះពាល់ គោលនយោបាយ និងក្របខណ្ឌការងារផ្លូវច្បាប់(ជាតិ និង អន្តរជាតិ) រួមបញ្ចូលទាំង យន្តការហិរញ្ញវត្ថុអាកាសធាតុ តើអាកាសធាតុវៃឆ្លាតជាអ្វី? ទស្សនៈនៃការសម្របខ្លួន និងការកាត់បន្ថយ ផែនការយុទ្ធសាស្ត្រ និងតំបន់អន្តរាគមន៍ក្នុងគម្រោងអាកាសធាតុវៃឆ្លាត វិធានការចំណាយតិច និងមិនចំណាយ និងរបៀបជួយគាំទ្រសហគមន៍ក្រីក្រនៅក្នុងទីក្រុង។ |

| ដំណើរការ | គោលបំណង | រយៈពេល (គិតជានាទី) |
|---|---|---|
| ចាប់ផ្តើមដោយការចុះហត្ថលេខានៅក្នុងក្រដាស់ ដែលបានចែកជូន | សកម្មភាពស្វាងអារម្មណ៍ ដើម្បីទាក់ទាញការចូលរួមនិង ណែនាំអ្នកចូលរួម | ១៥ |
| ការធ្វើបទបង្ហាញ | បង្ហាញដោយប្រើប្រាស់ផ្ទាំងស្លាយ | ៥០ |
| សំណួរសង្ខេប | សកម្មភាពក្រុម ដើម្បីរំលឹកមេរៀន | ១៥ |

## ភាគចុះហត្ថលេខា

## គោលបំណង និង ទិសដៅ

• សកម្មភាពសាមញ្ញៗដើម្បីធ្វើអោយអ្នកចូលរួមបានដឹងអំពីគោលបំណងពីគ្នាទៅវិញទៅមកហើយវាក៏ផ្តល់ឱកាសដើម្បីណែនាំអំពីប្រធានបទនៃវគ្គបណ្តុះបណ្តាល និងចំណាប់អារម្មណ៍ផ្សេងៗ

## សម្ភារៈ

• កាតរឹងសម្រាប់ចុះហត្ថលេខា មានចំនួនស្មើនឹងអ្នកចូលរួម (សូមមើលកាតគំរូខាងក្រោម)

## សកម្មភាពសម្របសម្រួល

• ចែកកាតទៅអ្នកចូលរួមម្នាក់មួយសន្លឹកដើម្បីចុះហត្ថលេខា

• ពន្យល់អ្នកចូលរួមទាំងអស់ហើយពួកគេមានពេលបីនាទី ដើម្បីសុំការចុះហត្ថលេខាពីអ្នកចូលរួមឱ្យបានចំនួន០៦នាក់ ប៉ុន្តែមានតែអ្នកដែលឆ្លើយសំណួរត្រូវប៉ុណ្ណោះទើបអាចចុះហត្ថលេខានៅលើកាតនោះបាន។ សូមលើកទឹកចិត្តឱ្យពួកគេដើរសុំការចុះហត្ថលេខាយ៉ាងសកម្មនៅក្នុងបន្ទប់នៃវគ្គបណ្តុះបណ្តាល។

• រយៈពេលបីនាទីក្រោយមក សូមអោយពួកគាត់បង្ហាញនូវកាតរបស់ខ្លួន និងលើកដៃ តើមានប៉ុន្មាននាក់ដែលទទួលបានអ្នកចុះហត្ថលេខាចំនួន០៦នាក់។

## ភាគចុះហត្ថលេខា

| ល.រ | សំណួរ | ហត្ថលេខា |
|---|---|---|
| ១ | តើនរណាជាអ្នកញែកកាកសំណល់ ឬសំរាមនៅផ្ទះ? | |
| ២ | តើនរណាជិះកង់? | |
| ៣ | តើនរណាប្រើប្រាស់អំពូលម៉ាក អិលអ៊ីឌី LED នៅផ្ទះ? | |
| ៤ | តើនរណាដឹងពីបញ្ហាសំរាមនៅភ្នំពេញ? | |
| ៥ | តើនរណាដឹងពីបរិមាណកាបូនឌីអុកស៊ីតដែលបំភាយចូលក្នុងបរិយាកាស? | |
| ៦ | តើនរណាគិតថា រដ្ឋាភិបាលអាចធ្វើការទប់ស្កាត់ការប្រែប្រួលអាកាសធាតុ? | |

## គំរូភាគចុះហត្ថលេខា

## បទបង្ហាញ

### គោលបំណង និងទិសដៅ

- ការណែនាំពីប្រធានបទ
- ចែករំលែកចំណេះដឹងទូទៅពីការប្រែប្រួលអាកាសធាតុ ដើម្បីស្វែងយល់ពីបរិបទនៃគម្រោងអាកាសធាតុវៃឆ្លាត
- បង្ហាញនូវទិដ្ឋភាពទូទៅពីយុទ្ធសាស្ត្រនៃគម្រោងអាកាសធាតុវៃឆ្លាតវៃ

### សម្ភារៈ

- ការធ្វើបទបង្ហាញដោយប្រើប្រាស់ផ្ទាំងស្លាយ នៃមេរៀនទី១

### ការរៀបចំបទបង្ហាញ

- ការធ្វើបទបង្ហាញអាចបត់បែនបានតាមអ្នកចូលរួម
- ស្លាយបទបង្ហាញខ្លះអាចកាត់ចោលបានក្នុងករណីមិនមានពេលគ្រប់គ្រាន់
- អ្នកធ្វើបទបង្ហាញត្រូវតែជាអ្នកដែលយល់ដឹងពាក់ព័ន្ធ នឹងប្រធានបទ ហើយប្រសិនបើអ្នកធ្វើបទបង្ហាញពុំមានចំណេះដឹងគ្រប់គ្រាន់ គេត្រូវតែស្រាវជ្រាវបន្ថែមដើម្បីស៊ីជំរៅនៃពីប្រធានបទ។

## ការធ្វើបទបង្ហាញ

- នៅពេលធ្វើបទបង្ហាញ ត្រូវព្យាយាមធ្វើយ៉ាងណាទាក់ទាញចំណាប់អារម្មណ៍អ្នកចូលរួម
- អ្នកត្រូវឆ្លើយ ប្រសិនបើ មានគេសួរនៅពេលបញ្ចប់បទបង្ហាញមេរៀននីមួយៗ
- លើកទឹកចិត្តអោយអ្នកចូលរួមធ្វើការចែករំលែកនូវអ្វីដែលគាត់ដឹងពីលើប្រធានបទ

## ការសង្ខេបសំណួរមេរៀន

## គោលបំណង និងទិសដៅ

- រំលឹកឡើងវិញនូវមាតិកាដែលបានធ្វើបទបង្ហាញ និងសង្ខេបមេរៀន
- ធ្វើសកម្មភាពសួរសំណួរជាក្រុម

## សម្ភារៈ

- ធ្វើបទបង្ហាញដោយប្រើប្រាស់ផ្ទាំងស្លាយនៃមេរៀនទី១
- ក្រដាសទំហំ អេ ហ្វ,A4ចំនួន៣សន្លឹកដែលមានអក្សរ អេ (A) ប៊ី (B) និង ស៊ី (C)

## សកម្មភាពសម្របសម្រួល

- បែងចែកអ្នកចូលរួមជាក្រុម ដោយក្នុងមួយក្រុមមានចំនួន៥នាក់
- ក្រុមនីមួយៗត្រូវរកនឹកដាក់ឈ្មោះបែបកំប្លែងៗ
- ចែកក្រដាសទំហំអេហ្វ,A4ចំនួន៣សន្លឹកដែលមានអក្សរ អេ(A)ប៊ី(B) និងស៊ី(C)ទៅក្រុមនីមួយៗ
- ពន្យល់អំពីសកម្មភាពសំណួរជាក្រុម និងផ្តល់រង្វាន់ជូនក្រុមដែលឈ្នះ
- ការធ្វើតេស្តសាកល្បង
- សួរសំណួរសាកល្បងទាំង៩សំណួរនៅលើផ្ទាំងស្លាយចំនួន៣

# មេរៀនទី២
# ការសង់លំនៅឋានដែលងាយសម្របខ្លួនទៅនឹងអាកាសធាតុក្តៅសើម

| មាតិកា៖ ការវិភាគអាកាសធាតុ កត្តាអាកាសធាតុដែលពាក់ព័ន្ធ នឹងការរចនាលំនៅឋាន ការសង់លំនៅឋានបែបបុរាណ យុទ្ធសាស្ត្រ និងវិធានការ៖ ការណែនាំ ការស្រូបខ្យល់ចេញចូល ម្លប់ អ៊ីសូឡង់ ការលាបថ្នាំដំបូលពណ៌ស ។ | | |
|---|---|---|
| **ដំណើរការ** | **គោលបំណង** | **រយៈពេល (គិតជានាទី)** |
| ការធ្វើបទបង្ហាញ | ផ្ទាំងស្លាយបង្ហាញមាតិកានៃមេរៀន | ៤០ |
| គម្រោងអាកាសធាតុ | អនុវត្តការងារជាក្រុម ដើម្បីអនុវត្តន៍នូវចំណេះដឹងថ្មីៗដែលទើបរៀន | ២០ |

## បទបង្ហាញ

### គោលបំណង និងទិសដៅ

- ស្វែងយល់ពីទំនាក់ទំនងរវាងអាកាសធាតុ និងការរចនាផ្ទះ
- ពន្យល់ឱ្យយល់ពីការសាងសង់ផ្ទះសម្របទៅនឹងអាកាសធាតុ ដោយប្រើគំរូផ្ទះបែបបុរាណ

### ស្ថាបត្យកម្មបែបទំនើប

- សិក្សាអំពីយុទ្ធសាស្ត្រសំខាន់ៗ ដើម្បីធ្វើផ្ទះឱ្យត្រជាក់ ក្នុងបរិយាកាសក្តៅ និងសើម។

### សម្ភារៈ

- ការធ្វើបទបង្ហាញដោយប្រើប្រាស់ផ្ទាំងស្លាយនៃមេរៀនទី២

### ការរៀបចំបទបង្ហាញ

- ការធ្វើការបទបង្ហាញអាចបត់បែនបានតាមអ្នកចូលរួម
- ស្លាយបទបង្ហាញខ្លះអាចកាត់ចោលបានក្នុងករណីមិនមានពេលគ្រប់គ្រាន់
- អ្នកធ្វើបទបង្ហាញត្រូវតែជាអ្នកដែលយល់ដឹងពាក់ព័ន្ធនឹងប្រធានបទ ហើយប្រសិនបើអ្នកធ្វើបទបង្ហាញពុំមានចំណេះដឹងគ្រប់គ្រាន់ គេត្រូវតែស្រាវជ្រាវបន្ថែមដើម្បីស៊ីជំរៅនៃពីប្រធានបទ។

## គម្រោងអាកាសធាតុ (អនុវត្តការងារជាក្រុម)

### គោលបំណង និង ទិសដៅ

• រំលឹកឡើងវិញនូវមាតិកាដែលបានធ្វើបទបង្ហាញ ហើយនិងអនុវត្តតាមឧទាហរណ៍ជាក់ស្តែង

### សម្ភារៈ

• បទបង្ហាញដោយប្រើប្រាស់ផ្ទាំងស្លាយនៃមេរៀនទី២

• ក្រដាសទំហំ អេហ្វ,A4 និង ការរចនាផ្ទះគំរូ (មើលរូបផ្ទះខាងក្រោម)

• ក្រដាសផ្ទាំងធំ (Flip chart) និង ហ្វឺត (ប៊ិចសរសេរលើក្តាខៀន)

### សកម្មភាពសម្របសម្រួល

• បែងចែកអ្នកចូលរួមជាក្រុម ដោយក្នុងមួយក្រុមមានចំនួន៥នាក់

• ក្រុមនីមួយៗទទួលបានការពិពណ៌នាអំពីការរចនាលំនៅឋានទំព័របន្ទាប់) ហើយធ្វើការកែលម្អឱ្យប្រសើរឡើងដើម្បីសម្របខ្លួនទៅនឹងធាតុអាកាស ដែលស្ថិតនៅក្នុងបរិបទនៃប្រទេសកម្ពុជា

• ក្រុមនីមួយៗត្រូវពិភាក្សាពី "ផ្ទះល្អ" និងរចនាផ្ទះនោះឱ្យវាប្រសើរឡើង

• ក្រុមនីមួយៗត្រូវសង្ខេបការពិភាក្សានិងសរសេរចំណុចកែសំរួលនៃផ្ទះនោះនៅលើក្រដាសផ្ទាំងធំ

• តំណាងក្រុមធ្វើបទបង្ហាញពីលទ្ធផលដែលបានពិភាក្សា ដោយមានរយៈ១០នាទីក្នុងការបង្ហាញ។

## រចនាតាមអាកាសធាតុ

### ផ្ទះគំរូ

### ការបរិយាយពីលក្ខណៈផ្ទះ

• ផ្ទះគំរូ មានទីតាំងស្ថិតនៅជាប់ប្រឡាយទឹក នៅលើដីដែលមានរយៈកំពស់ទាបបំផុត ហើយផ្ទះនោះទាបជាងផ្លូវចំនួន៣ម៉ែត្រ។ នៅរដូវវស្សា ទឹកប្រឡាយឡើង ហើយជួនកាលដីនោះត្រូវលិច

• ផែនការរចនាផ្ទះនេះឱ្យមានកំពស់១ម៉ែត្រពីប្រឡាយ ហើយទឹកជំនន់មានកំពស់កន្លះម៉ែត្រនៅរដូវប្រាំង

• ផ្ទះនេះមានទ្វារចូលពីខាងត្បូងដែលមានទំហំ១ម៉ែត្រ និង បង្អួចតូចមួយនៅខាងលិច

• ផ្ទះនេះស្រោបដោយលោហធាតុ ហើយវាគ្មានសំយ៉ាបទេ



## រូបទី១៖ ប្លង់ទីតាំង

ដំបូលមិនមានអ៊ីសូឡង់ (ស្រទាប់ការពារកំដៅ)។




រូបទី២៖ប្លង់ផ្ទះជាន់ផ្ទាល់ដី(ខាងឆ្វេង) និង មុខកាត់ អា-អា,A-A (ខាងស្តាំ)

ការងារដែលត្រូវធ្វើ៖

១. ពិភាក្សាពីគម្រោងកែលម្អផ្ទះ និងធ្វើតារាងកត់ត្រានូវអ្វីដែលមិនល្អ

២. កត់ត្រានូវអ្វីដែលត្រូវផ្លាស់ប្តូរនៃគម្រោងធ្វើផ្ទះ ដើម្បីសម្របទៅនឹងអាកាសធាតុ

៣. ពន្យល់គម្រោងផ្ទះដែលមានលក្ខណៈល្អប្រសើរជាមួយនឹងផ្ទះគំនូរ និងសរសេរនៅលើក្រដាសផ្ទាំងធំ។

# មេរៀនទី៣

# កាត់បន្ថយការប្រើប្រាស់ថាមពល និងថ្លៃចំណាយ

| មាតិកា៖ ថាមពល និង ការបំភាយឧស្ម័នពុល ការកាត់បន្ថយការចំណាយលើថាមពល យុទ្ធសាស្ត្រនិងវិធានការ៖ សូឡាពន្លឺដែលធ្វើពីដប ភ្លើងអំពូល ក្នុងនោះក៏ត្រូវការវិភាគការចំណាយ ចង្ក្រានឡូវ ថាមពលសូឡា ការប្រើប្រាស់កាបូនទាប និងសម្ភារៈកែច្នៃ។ | | |
|---|---|---|
| **ដំណើរការ** | **គោលបំណង** | **រយៈពេល (គិតជានាទី)** |
| វីដេអូឃ្លីប | ស្វែងយល់ពីទំនាក់ទំនងរវាងថាមពល និងការបំភាយឧស្ម័ន | ៥ |
| ការធ្វើបទបង្ហាញ | ស្លាយមេរៀនដើម្បីបង្ហាញពីមាតិកានៃមេរៀនទី៣ | ៣០ |
| វិធីសាស្ត្រទូទាត់ចំណាយ | លំហាត់អនុវត្តក្នុងក្រុមដែលឆ្លើយតាមទៅនឹងវិធីសាស្ត្រដែលបានរៀនថ្មីៗ | ១០ |

## វីដេអូឃ្លីប

### គោលបំណង និងទិសដៅ

- ការណែនាំពីប្រធានបទនៃមេរៀន
- វីដេអូឃ្លីបទី១៖ ស្វែងយល់ពីទំនាក់ទំនងរវាង ថាមពល និងការបំភាយឧស្ម័ន
- វីដេអូឃ្លីបទី២៖ តើអ្វីជាការសន្សំសំចៃថាមពល និងហេតុអ្វីបានជាវាមានសារៈសំខាន់ដើម្បីក្លាយទៅជាអាកាសធាតុវៃឆ្លាត។

### សម្ភារៈ

- វីដេអូឃ្លីបដែលបានយកមក(ដោនឡូត)ពីអ៊ីនធើណេត។

## ការធ្វើបទបង្ហាញ

### គោលបំណង និងទិសដៅ

- បង្ហាញចំណេះដឹងជុំវិញការប្រើប្រាស់ថាមពលនៅក្នុងគ្រួសារសហគមន៍ក្រីក្រ និងយុទ្ធសាស្ត្រក្នុងការកាត់បន្ថយការប្រើប្រាស់ថាមពល។

### សម្ភារៈ

- ស្លាយបទបង្ហាញនៃមេរៀនទី៣

## ការរៀបចំបទបង្ហាញ

- ការធ្វើបទបង្ហាញអាចបត់បែនបានតាមអ្នកចូលរួម
- ស្លាយបទបង្ហាញខ្លះអាចកាត់ចោលបានក្នុងករណីមិនមានពេលគ្រប់គ្រាន់
- អ្នកធ្វើបទបង្ហាញត្រូវតែជាអ្នកដែលយល់ដឹងពាក់ព័ន្ធនឹងប្រធានបទ ហើយប្រសិនបើអ្នកធ្វើបទបង្ហាញពុំមានចំណេះដឹងគ្រប់គ្រាន់ គេត្រូវតែស្រាវជ្រាវបន្ថែមដើម្បីស៊ីជំរៅនៃពីប្រធានបទ។

## ការធ្វើបទបង្ហាញ

- នៅពេលធ្វើបទបង្ហាញ ត្រូវព្យាយាមធ្វើយ៉ាងណាទាក់ទាញចំណាប់អារម្មណ៍អ្នកចូលរួម
- អ្នកត្រូវឆ្លើយ ប្រសិនបើ មានគេសួរនៅពេលបញ្ចប់បទបង្ហាញមេរៀននីមួយៗ
- លើកទឹកចិត្តអោយអ្នកចូលរួមធ្វើការចែករំលែកនូវអ្វីដែលគាត់ដឹងពីលើប្រធានបទ។

## វិធីគណនាការចំណាយ (ការងារជាក្រុម)

## គោលបំណង និងទិសដៅ

- ដើម្បីយល់ថា ហេតុអ្វីបានជាការសន្សំសំចៃថាមពលអាចចំណាយលើថ្លៃនៃការវិនិយោគបន្ថែមចំពោះការសន្សំសំចៃថាមពលតាមបែបបច្ចេកទេស។

## សម្ភារៈ

- ស្លាយបទបង្ហាញនៃមេរៀនទី៣ហើយពណ៌នាពីវិធីគណនាសំណង និងឧទាហរណ៍
- ការគណនាសំណងមាន ៣ករណីខុសៗគ្នា

## សកម្មភាពសម្របសម្រួល

- បែងចែកអ្នកចូលរួមជាក្រុម
- ចែកក្រដាសលំហាត់ដល់ក្រុមនីមួយៗ (មើលទំព័របន្ទាប់)
- មានតែរយៈពេល៥នាទីសម្រាប់ក្រុមនីមួយៗក្នុងការធ្វើលំហាត់
- អញ្ជើញតំណាងក្រុមធ្វើបទបង្ហាញនៃក្រុមនីមួយៗ ។

## វិធី គណនាការសំណេច

## លំហាត់ជាក្រុម

ករណីទី១៖ ការប្តូរអំពូលប្រភេទស៊ីអេហ្វអិល(CFL)ជំនួសដោយអំពូលប្រភេទអិលអ៊ីឌី (LED)មានគ្រួសារក្រីក្រមួយកំពុងប្រើប្រាស់អំពូលប្រភេទស៊ីអេហ្វអិល(CFL)ចំនួន៥អំពូល។អំពូលនីមួយៗមានកំលាំង២០វ៉ាត់ ហើយគេបើកវារយៈពេល១២ម៉ោងក្នុងមួយថ្ងៃ។ គ្រួសារក្រីក្រនោះគួរជំនួសអំពូលប្រភេទស៊ីអេហ្វអិលដោយជំនួសអំពូលប្រភេទ អិលអ៊ីឌីដែលមានកំលាំង៩វ៉ាត់វិញដែលមានតំលៃត្រឹមតែ១៤,០០០រៀលក្នុង១អំពូល។ តំលៃអគ្គិសនី១,៥០០ រៀលក្នុងមួយគីឡូវ៉ាត់ម៉ោង។

១. តើពួកគាត់អាចកាត់បន្ថយការចំណាយលើការប្រើប្រាស់ថាមពលបានប៉ុន្មានបើគាត់ជំនួសមកប្រើប្រាស់អំពូលប្រភេទអិលអ៊ីឌី(LED)ក្នុងមួយខែៗ?

២. តើគាត់ចំណាយរយៈពេលប៉ុន្មានម៉ោងក្នុងការសងសម្រាប់ការផ្លាស់ប្តូរអំពូលនោះ?

ករណីទី២៖ ចង្ក្រានសន្សំសំចៃថាមពល(ចង្ក្រានឡូវ)

មានគ្រួសារមួយកំពុងរស់នៅក្នុងសហគមន៍ក្រីក្រគាត់មានឆ្នាំងដាំបាយចាស់មួយដែលវាប្រើកំលាំងអគ្គិសនីចំនួន២១០គីឡូវ៉ាត់ម៉ោងក្នុង១ឆ្នាំ។ ដោយសារតែសហគមន៍គាត់មិនបានភ្ជាប់បណ្តាញអគ្គិសនីរដ្ឋគ្រួសារគាត់ត្រូវភ្ជាប់បណ្តាញអគ្គិសនីពីឯកជនដែលមានតម្លៃ០.៤ដុល្លារអាមេរិកក្នុងមួយគីឡូវ៉ាត់ម៉ោង។ ចំណែកឆ្នាំងបាយអគ្គិសនីថ្មីវិញប្រើកំលាំង១៦០គីឡូវ៉ាត់ម៉ោង ហើយវាមានតំលៃ៣០ដុល្លារអាមេរិក។

១. តើគ្រួសារក្រីក្រនោះអាចសន្សំថាមពលបានប៉ុន្មានក្នុងមួយឆ្នាំ ប្រសិនបើគាត់ប្រើចង្ក្រានសន្សំសំចៃ (ចង្ក្រានឡូវ)?

២. តើរយៈពេលប៉ុន្មានដែលការចំណាយនេះអាចសងរួចវិញ?

**ករណីទី១៖**

- អំពូលប្រភេទអ៊ិលអ៊ីឌី (LED)១ប្រើប្រាស់ភ្លើងតិចជាងអំពូលប្រភេទស៊ីអេហ្វអ៊ិល(CFL)១១វ៉ាត់។
- ការសន្សំសំចៃថាមពលប្រចាំខែ៖ ១១វ៉ាត់ x ៥(អំពូល) x១២ ម៉ោង x ៣០(ថ្ងៃ)

  = ១៩, ៨០០វ៉ាត់ម៉ោង =១៩.៨ គីឡូវ៉ាត់ម៉ោង

ចំលើយសំណួរទី១៖

- ការសន្សំសំចៃថ្លៃថាមពលប្រចាំខែ៖ ១៩,៨ គីឡូវ៉ាត់ x ១,៥០០ រៀល = ២៩,៧០០រៀល

ចំលើយសំណួរទី២៖

- ថ្លៃចំណាយសម្រាប់អំពូលប្រភេទអ៊ិលអ៊ីឌីថ្មីចំនួន៥ គឺ = ៥ x ១៤,000 = ៧0,000រៀល
- រយៈពេលដែលត្រូវទូទាត់សង = $\frac{\text{៧0,000 រៀល}}{\text{២៩,៧០០ រៀល}}$ = ២ ឆ្នាំ ៤ខែ

**ករណីទី២៖**

- ការសន្សំសំចៃថាមពល = ភាពខុសគ្នាក្នុងការប្រើប្រាស់ថាមពលប្រចាំឆ្នាំ៖ ២១០ គីឡូវ៉ាត់ម៉ោង១៦០ គីឡូវ៉ាត់ម៉ោង = ៦០ គីឡូវ៉ាត់ម៉ោង។

ចំលើយសំណួរទី១៖

- ការសន្សំសំចៃថ្លៃថាមពល៖ ៦០គីឡូវ៉ាត់ម៉ោង x ០.៤ ដុល្លារ (ថ្លៃភ្លើង) = ២៤ដុល្លារអាមេរិក

ចំលើយសំណួរទី២៖

- ថ្លៃចង្ក្រានសន្សំសំចៃ៖ ៣០ដុល្លារអាមេរិក
- រយៈពេលដែលត្រូវទូទាត់សង = $\frac{\text{៣០ ដុល្លា}}{\text{២៤ ដុល្លា}}$ = ១ ឆ្នាំ ៣ ខែ

# មេរៀនទី៤
# ការគ្រប់គ្រងកាកសំណល់រឹង ឬសំរាម និង ការបង្កើតតំបន់បៃតង

| |
|---|
| មាតិកា៖ ស្ថានភាពបច្ចុប្បន្ន ទស្សនៈ ៣R (អ៣) យុទ្ធសាស្ត្រ និង វិធានការ៖ ទិវាសំអាតសហគមន៍ និង ការញែកសំរាម ទីតាំងប្រមូលសំរាម ការធ្វើជីកំប៉ុស សួនបន្លែ ឡជីវឧស្ម័ន ជញ្ជាំងដែលធ្វើពីដបប្លាស្ទិក។ |

| ដំណើរការ | គោលបំណង | រយៈពេល (គិតជានាទី) |
|---|---|---|
| ការធ្វើបទបង្ហាញ | ស្លាយដើម្បីបង្ហាញនៃមេរៀនទី៤ | ៥០ |
| សំណួរសង្ខេប | សកម្មភាពក្រុមដើម្បីរំលឹកមាតិកានៃបទបង្ហាញ | ១០ |

## ការធ្វើបទបង្ហាញ

## គោលបំណង និង ទិសដៅ

- ណែនាំពីប្រធានបទ
- ចែករំលែកចំណេះដឹងទាក់ទងការគ្រប់គ្រងកាកសំណល់រឹង ឬសំរាម និង គោលការណ៍សំខាន់ៗ
- ស្វែងយល់ពីយុទ្ធសាស្ត្រអាកាសធាតុវៃឆ្លាតដើម្បីបង្កើនការគ្រប់គ្រងកាកសំណល់រឹងឬសំរាមនៅក្នុងសហគមន៍ក្រីក្រ។

## សម្ភារៈ

- បទបង្ហាញផ្ទាំងស្លាយនៃមេរៀនទី៤

## ការរៀបចំបទបង្ហាញ

- ការធ្វើការបទបង្ហាញអាចបត់បែនបានតាមអ្នកចូលរួម
- ស្លាយបទបង្ហាញខ្លះអាចកាត់ចោលបានក្នុងករណីមិនមានពេលគ្រប់គ្រាន់
- អ្នកធ្វើបទបង្ហាញត្រូវតែជាអ្នកដែលយល់ដឹងពាក់ព័ន្ធនឹងប្រធានបទ ហើយប្រសិនបើអ្នកធ្វើបទបង្ហាញពុំមានចំណេះដឹងគ្រប់គ្រាន់ គេត្រូវតែស្រាវជ្រាវបន្ថែមដើម្បីស៊ីជំរៅនៃពីប្រធានបទ។

## ការធ្វើបទបង្ហាញ

- នៅពេលធ្វើបទបង្ហាញ ត្រូវព្យាយាមធ្វើយ៉ាងណាទាក់ទាញចំណាប់អារម្មណ៍អ្នកចូលរួម
- អ្នកត្រូវឆ្លើយ ប្រសិនបើ មានគេសួរនៅពេលបញ្ចប់បទបង្ហាញមេរៀននីមួយៗ
- លើកទឹកចិត្តអោយអ្នកចូលធ្វើការចូលរួមចែករំលែកនូវអ្វីដែលគាត់ដឹងពីលើប្រធានបទ។

# សង្ខេបសំណួរតាមក្រុម

## គោលបំណង និងទិសដៅ

- រំលឹកឡើងវិញនូវអ្វីដែលបានបង្ហាញ និងសង្ខេបមេរៀន
- រៀបចំសំណួរក្រុម

## សម្ភារៈ

- បទបង្ហាញស្លាយនៃមេរៀនទី៤
- ក្រដាសទំហំ អេហ្វ,A4ចំនួន៣សន្លឹកដែលមានអក្សរ អេ (A) ប៊ី (B) និង ស៊ី (C)
- បែងចែកអ្នកចូលរួមជាក្រុម ដោយក្នុង១ក្រុមមានចំនួន៥នាក់
- ក្រុមនីមួយៗត្រូវរកនឹកដាក់ឈ្មោះបែបកំប្លែងៗអាចយកក្រុមដដែលបានបែងចែកនៅមេរៀនទី១
- ចែកក្រដាសទំហំ អេហ្វ,A4ចំនួន ៣សន្លឹកដែលមានអក្សរ អេ (A) ប៊ី (B) និង ស៊ី (C)

ទៅក្រុមនីមួយៗ

- ពន្យល់សំណួរដល់ក្រុមនីមួយៗ និងផ្តល់រង្វាន់ជូនអ្នកដែលឈ្នះ
- មិនមានការធ្វើតេសសាកល្បង ដូចនៅមេរៀនទី១នោះទេ

# មេរៀនទី៥
# ទឹក និង បង្គន់អនាម័យ

| | | |
|---|---|---|
| មាតិកា៖ ការទទួលបានទឹកស្អាត និង បង្គន់អនាម័យ ស្ថានភាពបច្ចុប្បន្ន យុទ្ធសាស្ត្រ និង វិធានការ៖ ការប្រមូលទឹកភ្លៀង ធុងចំរោះទឹកសេរ៉ាមិច ការចំរោះទឹកស្អុយតាមធម្មជាតិ ការការពារទឹកជំនន់។ | | |
| **ដំណើរកាល** | **គោលបំណង** | **រយៈពេល (គិតជានាទី)** |
| ការធ្វើបទបង្ហាញ | ផ្ទាំងស្លាយសម្រាប់បង្ហាញមាតិកានៃមេរៀន | ៤៥ |
| ការពិភាក្សាជាក្រុម | ការស្រាវជ្រាវជាក្រុមលើប្រធានបទនៃមេរៀន | ១៥ |

## បទបង្ហាញ

### គោលបំណង និង ទិសដៅ

- ស្វែងយល់ពីសារៈសំខាន់នៃការទទួលបានទឹកស្អាត និង បង្គន់អនាម័យ
- ចែករំលែកចំណេះដឹងដែលទាក់ទងទៅនឹងប្រធានបទ
- ស្វែងយល់ពីយុទ្ធសាស្ត្រអាកាសធាតុវៃឆ្លាតដើម្បីធានាថា សហគមន៍ក្រីក្រនឹងទទួលបានទឹកស្អាត និងបង្គន់អនាម័យប្រើប្រាស់ ។

### ការរៀបចំបទបង្ហាញ

- ការធ្វើការបទបង្ហាញអាចបត់បែនបានតាមអ្នកចូលរួម
- ស្លាយបទបង្ហាញខ្លះអាចកាត់ចោលបានក្នុងករណីមិនមានពេលគ្រប់គ្រាន់
- អ្នកធ្វើបទបង្ហាញត្រូវតែជាអ្នកដែលយល់ដឹងពាក់ព័ន្ធនឹងប្រធានបទ ហើយប្រសិនបើអ្នកធ្វើបទបង្ហាញពុំមានចំណេះដឹងគ្រប់គ្រាន់ គេត្រូវតែស្រាវជ្រាវបន្ថែមដើម្បីស៊ីជំរៅនៃពីប្រធានបទ។

### ការធ្វើបទបង្ហាញ

- នៅពេលធ្វើបទបង្ហាញ ត្រូវព្យាយាមធ្វើយ៉ាងណាទាក់ទាញចំណាប់អារម្មណ៍អ្នកចូលរួម
- អ្នកត្រូវឆ្លើយ ប្រសិនបើមានគេសួរនៅពេលបញ្ចប់បទបង្ហាញមេរៀននីមួយៗ
- លើកទឹកចិត្តអោយអ្នកចូលធ្វើការចូលរួមចែករំលែកនូវអ្វីដែលគាត់ដឹងពីលើប្រធានបទ។

## ការពិភាក្សាតាមក្រុម

### គោលបំណង និងទិសដៅ

- ការស្រាវជ្រាវឱ្យចំប្រធានបទនៃមេរៀន
- រៀបចំសកម្មភាពជាក្រុម

### សម្ភារៈ

- ផ្ទាំងស្លាយបទបង្ហាញនៃមេរៀនទី
- ក្រដាសសម្រាប់សរសេរសង្ខេបនូវអ្វីក្រុមពិភាក្សាបានរកឃើញ

### សកម្មភាពសម្របសម្រួល

- បែងចែកអ្នកចូលរួមជាក្រុម ដោយក្នុង១ក្រុមមានចំនួន៥នាក់
- ក្រុមនីមួយៗមានរយៈពេលតែ០៧នាទី ដើម្បីពិភាក្សាលើសំណួរមួយឱ្យស៊ីជំរៅ
- អញ្ជើញតំណាងក្រុមធ្វើបទបង្ហាញលទ្ធផលក្នុងរយៈពេលតែ០៣នាទី

# មេរៀនទី៦
# ការធ្វើផែនការ និងការអនុវត្តការកែលម្អអាកាសធាតុវៃឆ្លាត

**មាតិកា៖** តើធ្វើយ៉ាងណាដើម្បីអោយសហាគមន៍មានការយល់ដឹង និង ចូលរួមការកែលម្អអាកាសធាតុវៃឆ្លាត? តើត្រូវបង្កើតផែនការអភិវឌ្ឍអាកាសធាតុវៃឆ្លាតបែបណា ដើម្បីគាំទ្រដល់គ្រួសារសហាគមន៍ក្រីក្រជាក់ស្តែង? ការកំណត់កញ្ចប់ថវិកា និង ផែនការសកម្មភាព?

| ដំណើរការ | គោលបំណង | រយៈពេល (គិតជានាទី) |
|---|---|---|
| ក្រុមពិភាក្សា | វិធីសាស្រ្តស្វែងរកអ្នកចូលរួមដើម្បីអោយសហាគមន៍បានយល់ដឹង និង ចូលរួមនៅក្នុងការកែលម្អអាកាសធាតវៃឆ្លាត។ | ១៥ |
| ការធ្វើបទបង្ហាញ | ការបង្ហាញផ្ទាំងស្លាយបទបង្ហាញមាតិកានៃមេរៀន | ១៥ |
| វិធីសិក្សាតាមការដើរមើលរូបភាព (Gallery Walk) | ការពិភាក្សាជាក្រុម ដោយប្រើវិធីសាស្រ្តនៃការចូលរួមដើម្បីបង្កើតផែនការអភិវឌ្ឍនៃអាកាសធាតុវៃឆ្លាតចំពោះសហាគមន៍ក្រីក្រ ក្នុងករណីមានឧទាហរណ៍។ | ៣០ |

## ក្រុមពិភាក្សា

### គោលបំណង និងទិសដៅ

- វិធីសាស្រ្តស្វែងរកអ្នកចូលរួមដើម្បីអោយសហាគមន៍បានយល់ដឹង និង ចូលរួមនៅក្នុងការកែលម្អអាកាសធាតុវៃឆ្លាត។

### សម្ភារៈ

- សំណួរណែនាំនៅក្នុងផ្ទាំងស្លាយបទបង្ហាញនៃមេរៀន សំណួរណែនាំសម្រាប់ក្រុមពិភាក្សា
- ចែករំលែកបទពិសោធន៍ផ្ទាល់របស់ដែលអាចទាក់ទាញគ្រួសារសហាគមន៍ក្រីក្រ
- មើលគ្រប់ចំណុចសំខាន់ៗនៃគម្រោងអាកាសធាតុវៃឆ្លាត តើប្រធានបទមួយណាដែលបន្ទាន់សម្រាប់ពួកគាត់? ហេតុអ្វី?
- តើយើងអាចជួយអោយគាត់យល់អំពីសារៈសំខាន់ នៃការឆ្លើយតបដោយឆ្លាតវៃទៅនឹងការប្រែប្រួលអាកាសធាតុ ដោយរបៀបណា?
- តើវិធីណាដែលល្អ ដើម្បីទាក់ទាញសហាគមន៍ទៅនឹងការអភិវឌ្ឍអាកាសធាតុវៃឆ្លាត?

## បទបង្ហាញ

### គោលបំណង និងទិសដៅ

- សិក្សាពីការចូលរួមរបស់សហគមន៍ និង សកម្មភាពលើកកំពស់ការយល់ដឹង
- សិក្សាពីរបៀបបង្កើតផែនការអភិវឌ្ឍអាកាសធាតុវៃឆ្លាត
- ឧបករណ៍អនុវត្តន៍សម្រាប់ការប៉ាន់ស្មានកញ្ចប់ថវិកា ការកំណត់ផែនការសកម្មភាពដើម្បីអនុវត្តន៍។

### សម្ភារៈ

- ផ្ទាំងស្លាយបទបង្ហាញនៃមេរៀន

### ការរៀបចំបទបង្ហាញ

- ការធ្វើការបទបង្ហាញអាចបត់បែនបានតាមអ្នកចូលរួម
- ស្លាយបទបង្ហាញខ្លះអាចកាត់ចោលបានក្នុងករណីមិនមានពេលគ្រប់គ្រាន់
- អ្នកធ្វើបទបង្ហាញត្រូវតែជាអ្នកដែលយល់ដឹងពាក់ព័ន្ធនឹងប្រធានបទ ហើយប្រសិនបើអ្នកធ្វើបទបង្ហាញពុំមានចំណេះដឹងគ្រប់គ្រាន់ គេត្រូវតែស្រាវជ្រាវបន្ថែមដើម្បីស៊ីជំរៅពីប្រធានបទ។

### ការធ្វើបទបង្ហាញ

- នៅពេលធ្វើបទបង្ហាញ ត្រូវព្យាយាមធ្វើយ៉ាងណាទាក់ទាញចំណាប់អារម្មណ៍អ្នកចូលរួម
- អ្នកត្រូវឆ្លើយ ប្រសិនបើ មានគេសួរនៅពេលបញ្ចប់បទបង្ហាញមេរៀននីមួយៗ
- លើកទឹកចិត្តអោយអ្នកចូលធ្វើការចូលរួមចែករំលែកនូវអ្វីដែលគាត់ដឹងពីលើប្រធានបទ។

## វិធីសិក្សាតាមការដើរមើលរូបភាព *(Gallery Walk)*

### គោលបំណង និង ទិសដៅ

- ការពិភាក្សាជាក្រុម ដោយប្រើវិធីសាស្រ្តនៃការចូលរួមដើម្បីបង្កើតផែនការអភិវឌ្ឍនៃអាកាសធាតុវៃឆ្លាតចំពោះសហគមន៍ក្រីក្រក្នុងករណីជាមានឧទាហរណ៍។

### ការពិពណ៌នាអំពីវិធីសាស្រ្ត

- របៀបនៃការពិភាក្សានេះ អនុញ្ញាតអោយអ្នកចូលរួមមានសកម្មភាពយ៉ាងរស់រវើកនៅក្នុងថ្នាក់រៀន
- ពួកគាត់ទាំងអស់ធ្វើការជាក្រុម ដើម្បីចែករំលែកការយល់ឃើញ និង ឆ្លើយរាល់សំណួរ ឯកសាររូបភាព និង ការដោះស្រាយបញ្ហាតាមស្ថានភាព ឬអត្ថបទ ។

### សម្ភារៈ

- ក្រដាសផ្ទាំងធំចំនួន០៥ផ្ទាំង ជាមួយនឹងករណីសិក្សាពីសហគមន៍ក្រីក្រខុសៗគ្នា និងសំណួរចំៗសម្រាប់បង្កើតផែនការសកម្មភាពគម្រោងអាកាសធាតុវៃឆ្លាត(មើលតារាងខាងក្រោម)
- ថតចំលងករណីចំនួន៥-១០សន្លឹក ដែលពណ៌នាករណីសិក្សានីមួយៗ (មើលតារាងខាងក្រោម)
- ហ្វឺត ក្រដាសពណ៌ចំរុះ និង បិទករណីសិក្សានៃទីតាំងទាំងអស់នៅលើជញ្ជាំង

### សកម្មភាពសម្របសម្រួល

- បិតក្រដាសផ្ទាំងធំ(ទីតាំង)នៅលើជ្រុងជញ្ជាំងខុសៗគ្នានៅក្នុងបន្ទប់រៀន
- បែងចែកអ្នកចូលរួមជា០៥ក្រុម
- ក្រុមនីមួយៗចាប់ផ្តើមធ្វើការនៅលើករណីសិក្សានៃទីតាំងខុសៗគ្នា និងពិភាក្សា និង បន្ថែមដំណោះស្រាយសម្រាប់ផែនការសកម្មភាពអាកាសធាតុវៃឆ្លាតដល់អ្នកក្រីក្រ
- ក្រោយរយៈពេល០៥នាទី ក្រុមនីមួយៗត្រូវផ្លាស់ប្តូរទៅទីតាំងករណីសិក្សាថ្មីមួយទៀតដោយចាប់ផ្តើមអាននូវលទ្ធផលរបស់ក្រុមពិភាក្សាមុន និងបញ្ចូលនូវមាតិកាបន្ថែមទៀត
- ដំបូងត្រូវអានម្តងទៀតនៃក្រុមនីមួយៗដែលបានបន្ថែមមាតិកាថ្មីៗចំពោះទីតាំងករណីសិក្សនីមួយៗ
- ជំហានចុងក្រោយក្រុមនីមួយៗត្រូវទីតាំងករណីសិក្សាដែលបានចាប់ផ្តើម ត្រូវធ្វើការវិភាគនូវអ្វីដែលបានបន្ថែម និងរាយការណ៍ដោយមាត់ទទេ។
- ចុងក្រោយនៃការដើរមើលរូបភាព Gallery Walk គឺជាការផ្លាស់ប្តូរសម្រាប់ការចូលរួមនៅក្នុងបន្ទប់រៀនចំពោះការពិភាក្សា និងលើកឡើងនូវអ្វីដែលច្រឡំ។

### ទីតាំងទី១៖ ករណីការសិក្សា សហគមន៍ទី១

ក្រុមពិភាក្សា ដោយការដើរមើលតាមជញ្ជាំង (Gallery Walk)

ការពិពណ៌នាពីសហគមន៍៖

សហគមន៍មួយមានទីតាំងជិតបឹងទំពុន ផ្ទះពួកគាត់កំពុងរស់នៅលើបឹង ហើយភាគច្រើនមានបង្គន់ ប៉ុន្តែ ប្រព័ន្ធលូ និងទឹកស្អុយគឺពួកគាត់បង្ហូរចូលដោយផ្ទាល់ចូលក្នុងបឹង។ ពួកគាត់បានភ្ជាប់បណ្តាញអគ្គិសនី របស់រដ្ឋ តែមិនបានតភ្ជាប់បណ្តាញទឹករដ្ឋទេ ពីព្រោះវាមានតម្លៃថ្លៃ។ ដូច្នេះ ពួកគាត់យកទឹកបឹងសម្រាប់ប្រើប្រាស់ប្រចាំថ្ងៃ។ គ្រួសារមួយចំនួនមិនមានលទ្ធភាពទិញទឹកស្អាតប្រើប្រាស់(ផឹក) គឺពួកគាត់ប្រើប្រាស់ទឹកបឹងសម្រាប់ផឹក។ នៅសហគមន៍ទីមួយឃើញថា ទឹកបឹងដែលពួកគាត់កំពុងតែយកមកផឹក និងប្រើប្រាស់ប្រចាំថ្ងៃនោះវាមានជាតិពុល និងក្លិនស្អុយ។

សំណួរ៖

១. តើអ្វីជាបញ្ហាចម្បងរបស់សហគមន៍?

២. តើគម្រោងកែលម្អអាកាសធាតុវៃឆ្លាតមួយណាដែលអ្នកស្នើសុំ?

៣. តើការបង្កើតផែនការអភិវឌ្ឍនៃអាកាសធាតុវៃឆ្លាតដូចម្តេច សម្រាប់សហគមន៍អ្នកក្រីក្រ?

សូមប្រើតារាងគំរូខាងក្រោម៖

| **គោលដៅ** | | | |
|---|---|---|---|
| **សូចនាករ** | | | |
| **កិច្ចការដែលត្រូវធ្វើ** | **ធនធាន** | **ការទទួលខុសត្រូវ** | **កាលបរិច្ឆេទ** |
| | | | |
| | | | |
| | | | |

### ទីតាំងទី២៖ ករណីការសិក្សា សហគមន៍ទី២

ក្រុមពិភាក្សា ដោយការដើរមើលតាមជញ្ជាំង(Gallery Walk)

ការពិពណ៌នាពីសហគមន៍៖

លំនៅដ្ឋានសហគមន៍ទី២នេះស្ថានភាពរស់នៅមិនសូវល្អ។ ផ្ទះភាគច្រើនគ្មានបង្អួច ឬមានតែបង្អួចតូចមួយ សមាជិកសហគមន៍បានលើកឡើងថា ការរស់នៅក្នុងផ្ទះវាក្តៅ។ ពេលថ្ងៃគឺស្ទើរតែមិនអាចរស់នៅក្នុងផ្ទះនោះបានឡើយ។ នៅក្នុងផ្ទះវាងងឹតហើយពួកគេត្រូវបើកភ្លើងពេញមួយថ្ងៃនៅពេលថ្ងៃ។ ក្រៅពីលំនៅឋានស្ថានភាពរស់នៅមិនល្អ ពួកគេត្រូវបង់ថ្លៃភ្លើងថ្លៃពីព្រោះពួកគេមិនបានតភ្ជាប់បណ្តាញអគ្គិសនីរបស់រដ្ឋ(EDC)។ ប៉ុន្តែ ពួកគេភាគច្រើនតភ្ជាប់បណ្តាញអគ្គិសនីពីឯកជនដែលមានតំលៃរហូតដល់ទៅ ៣,២០០រៀលក្នុងមួយគីឡូវ៉ាត់ម៉ោង។ នៅផ្ទះនីមួយៗវិញមានប្រើប្រាស់អំពូលយ៉ាងតិច៤អំពូល ហើយក្នុងនោះមានផ្ទះខ្លះប្រើប្រាស់អំពូលពងមាន់៦០វ៉ាត់ (Incandescent) និងខ្លះទៀតប្រើប្រាស់អំពូលអ៊ុយ ១៩ វ៉ាត់ (CFL)។

សំណួរ៖

១. តើអ្វីជាបញ្ហាចម្បងរបស់សហគមន៍?

២. តើគម្រោងកែលម្អអាកាសធាតុវៃឆ្លាតមួយណាដែលអ្នកស្នើសុំ?

៣. តើការបង្កើតផែនការអភិវឌ្ឍនៃអាកាសធាតុវៃឆ្លាតដូចម្តេច សម្រាប់សហគមន៍អ្នកក្រីក្រ?

សូមប្រើតារាងគំរូខាងក្រោម៖

តារាងគំរូផែនការអភិវឌ្ឍនៃគម្រោងអាកាសធាតុវៃឆ្លាតសម្រាប់អ្នកក្រីក្រ៖

| **គោលដៅ** | | | |
|---|---|---|---|
| **សូចនាករ** | | | |
| **កិច្ចការដែលត្រូវធ្វើ** | **ធនធាន** | **ការទទួលខុសត្រូវ** | **កាលបរិច្ឆេទ** |
| | | | |
| | | | |
| | | | |

### ទីតាំងទី៣៖ ករណីការសិក្សា សហគមន៍ទី៣

ក្រុមពិភាក្សា ដោយការដើរមើលតាមជញ្ជាំង (Gallery Walk)

ការពិពណ៌នាពីសហគមន៍៖

សហគមន៍នេះជាសហគមន៍តាំងទីលំនៅថ្មី។ ផ្ទះរបស់ពួកគាត់សុទ្ធតែថ្មី ពីព្រោះពួកគាត់បានទទួលសំណងគ្រប់គ្រាន់ដើម្បីសាងសង់វា។ទោះបីជាយ៉ាងណាក៏ដោយ សហគមន៍មានបញ្ហាធំគឺបញ្ហាកាកសំណល់រឹង ឬសំរាម។ យើងឃើញមានសំរាមចង់ប្លាស្ទិកនៅពាសពេញសហគមន៍។ទោះពីជាយ៉ាងណាក៏ដោយ សំរាមមានទីតាំងប្រមូលសំរាមតែមួយគត់សម្រាប់ប្រមូលពីផ្លូវធំក្នុងពី សហគមន៍ដែលវាស្ថិតនៅមិនឆ្ងាយពីសហគមន៍នោះ។ សហគមន៍ មានអ្នកបើកអាជីវកម្មម្ហូបអាហារជាច្រើនកន្លែង ពីអាជីកម្មនេះពួកគេអាចប្រើប្រាស់កាកសំណល់ជីសរីរាង្គហើយអាចយកទៅធ្វើឡឧស្ម័នបាន។ នៅជាប់សហគមន៍នោះ មានកន្លែងទំនេរជាច្រើនដែលអាចអនុវត្តន៍ធ្វើជីកំប៉ុសហើយអ្វីដែលបញ្ហាជាបញ្ហាប្រឈមរបស់សហគមន៍នោះគឺ ការគ្រប់គ្រងកាកសំណល់រឹង ឬសំរាម។

សំណួរ៖

១. តើអ្វីជាបញ្ហាចម្បងរបស់សហគមន៍?

២. តើគម្រោងកែលម្អអាកាសធាតុវៃឆ្លាតមួយណាដែលអ្នកស្នើសុំ?

៣. តើការបង្កើតផែនការអភិវឌ្ឍនៃអាកាសធាតុវៃឆ្លាតដូចម្ដេច សម្រាប់សហគមន៍អ្នកក្រីក្រ?

សូមប្រើតារាងគំរូខាងក្រោម៖

តារាងគំរូផែនការអភិវឌ្ឍនៃគម្រោងអាកាសធាតុវៃឆ្លាតសម្រាប់អ្នកក្រីក្រ៖

| គោលដៅ | | | |
|---|---|---|---|
| សូចនាករ | | | |
| កិច្ចការដែលត្រូវធ្វើ | ធនធាន | ការទទួលខុសត្រូវ | កាលបរិច្ឆេទ |
| | | | |
| | | | |
| | | | |

### ទីតាំងទី៤៖ ករណីការសិក្សា សហគមន៍ទី៤

ក្រុមពិភាក្សា ដោយការដើរមើលតាមជញ្ជាំង (Gallery Walk)

ការពិពណ៌នាពីសហគមន៍៖

អង្គការរបស់អ្នកកំពុងបង្កើតគំរោងមួយដើម្បីស្នើសុំមូលនិធិស្តីពី គឺគម្រោងការគ្រប់គ្រងកាកសំណល់អាកាសធាតុវៃឆ្លាតដល់សហគមន៍ក្រីក្រក្នុងទីក្រុង។ អ្នកបានចុះទៅមើលសហគមន៍ជាក់ស្តែង ហើយបានឃើញថាសហគមន៍នោះមានបញ្ហាចម្បងគឺកាកសំណល់រឹងឬសំរាម។ផ្ទះភាគច្រើនសង់ដោយប្រើសសរ។ នៅក្រោមផ្ទះឃើញសុទ្ធតែដបប្លាស្ទិកចាស់ៗនិងសំរាមផ្សេងៗទៀតជាច្រើន។ ប៉ុន្តែ មានអង្គការកំពុងមានគម្រោងសាងសង់មជ្ឈមណ្ឌលតូចមួយនៅក្នុងសហគមន៍ផងដែរ។

សំណួរ៖

១. តើអ្វីជាបញ្ហាចម្បងរបស់សហគមន៍?

២. តើគម្រោងកែលម្អអាកាសធាតុវៃឆ្លាតមួយណាដែលអ្នកស្នើសុំ?

៣. តើការបង្កើតផែនការអភិវឌ្ឍនៃអាកាសធាតុវៃឆ្លាតដូចម្តេច សម្រាប់សហគមន៍អ្នកក្រីក្រ?

សូមប្រើតារាងគំរូខាងក្រោម៖

តារាងគំរូផែនការអភិវឌ្ឍនៃគម្រោងអាកាសធាតុវៃឆ្លាតសម្រាប់អ្នកក្រីក្រ៖

| | | | |
|---|---|---|---|
| **គោលដៅ** | | | |
| **សូចនាករ** | | | |
| **កិច្ចការដែលត្រូវធ្វើ** | **ធនធាន** | **ការទទួលខុសត្រូវ** | **កាលបរិច្ឆេទ** |
| | | | |
| | | | |
| | | | |

## ទីតាំងទី៥៖ ករណីការសិក្សា សហគមន៍ទី៥

ក្រុមពិភាក្សា ដោយការដើរមើលតាមជញ្ជាំង (Gallery Walk)

ការពិពណ៌នាពីសហគមន៍៖

សហគមន៍ទី៥នេះមិនបានតភ្ជាប់បណ្តាញទាំងពីរទឹកនិងអគ្គិសនីរដ្ឋនោះទេ។ដូច្នេះគ្រួសារទាំងអស់បានបង់ថ្លៃ ទឹក និងអគ្គិសនីដែលមានតម្លៃថ្លៃទៅឱ្យឯកជន។ មិនមានគ្រួសារណាមួយធ្លាប់បានទាក់ទងទៅអគ្គិសនីកម្ពុជា(EDC)ដើម្បីតភ្ជាប់បណ្តាញអគ្គិសនីរដ្ឋនោះទេ។ ម្យ៉ាងវិញទៀតក៏ទាន់មានអ្នកណាដែលអាចជួយបង់ថ្លៃដើម្បីតភ្ជាប់បណ្តាញអគ្គិសនីរដ្ឋដល់ពួកគេនោះទេ។ ការតភ្ជាប់បណ្តាញទឹករដ្ឋវាមានការលំបាកប៉ុន្តែអ្នកអាចស្នើសុំការចុះតម្លៃនៃការបង់ថ្លៃទឹក។ ជាមធ្យមពួកគេប្រើប្រាស់អំពូលយ៉ាងតិចចំនួន៤ (ប្រភេទ ស៊ីអេហ្វអិល) ដែលវាស៊ីភ្លើង១៥ វ៉ាត់ ហើយបើកវាយ៉ាងតិច៥ម៉ោងក្នុងមួយថ្ងៃ។

### សំណួរ៖

១. តើអ្វីជាបញ្ហាចម្បងរបស់សហគមន៍?

២. តើគម្រោងកែលម្អអាកាសធាតុវៃឆ្លាតមួយណាដែលអ្នកស្នើសុំ?

៣. តើការបង្កើតផែនការអភិវឌ្ឍនៃអាកាសធាតុវៃឆ្លាតដូចម្តេច សម្រាប់សហគមន៍អ្នកក្រីក្រ?

សូមប្រើតារាងគំរូខាងក្រោម៖

តារាងគំរូផែនការអភិវឌ្ឍនៃគម្រោងអាកាសធាតុវៃឆ្លាតសម្រាប់អ្នកក្រីក្រ៖

| **គោលដៅ** | | | |
|---|---|---|---|
| **សូចនាករ** | | | |
| **កិច្ចការដែលត្រូវធ្វើ** | **ធនធាន** | **ការទទួលខុសត្រូវ** | **កាលបរិច្ឆេទ** |
| | | | |
| | | | |
| | | | |

# ឧបសម្ព័ន្ធ៖ រូបភាពសកម្មភាព

## រូបភាពទី១៖



ការធ្វើបង្ហាញពីគម្រោងអាកាសធាតុវៃឆ្លាត
ដល់សហគមន៍រលួសជើងឯក



ការធ្វើបង្ហាញពីគម្រោងអាកាសធាតុវៃឆ្លាត
ដល់សហគមន៍រលួសជើងឯក

## រូបភាពទី២៖



ការធ្វើបង្ហាញពីគម្រោងអាកាសធាតុវៃឆ្លាត
ដល់សហគមន៍សាមគ្គីរុងរឿង

រូបថតអ្នកចូលរួមនៃសហគមន៍រលួសជើងឯក និងសាមគ្គីរុងរឿងក្រោយបទបង្ហាញពីគម្រោងអាកាសធាតុវៃឆ្លាត ឆ្នាំ២០១៧

## រូបភាពទី៣៖



ការធ្វើបង្ហាញពីគម្រោងអាកាសធាតុវៃឆ្លាត ដល់សហគមន៍ត្រពាំងរាំង



ការធ្វើបង្ហាញពីគម្រោងអាកាសធាតុវៃឆ្លាត ដល់សហគមន៍ត្រពាំងរាំង

ការធ្វើបង្ហាញពីគម្រោងអាកាសធាតុវៃឆ្លាតដល់សហគមន៍ ត្រពាំងរាំង ឆ្នាំ២០១៨

## រូបភាពទី៤៖



ការចែកធុងសំរាមដល់សហគមន៍រលួសជើងឯក



ការចែកធុងសំរាមដល់សហគមន៍សាមគ្គីរុងរឿង

ការចែកធុងសំរាមដល់សហគមន៍រលួសជើងឯក និងសហគមន៍សាមគ្គីរុងរឿង

# សទ្ទានុក្រម

| ខ្នាតបំព្រួញ | អត្ថន័យ |
|---|---|
| គ.ម | គីឡូម៉ែត្រ(គឺជាខ្នាតប្រវែងដែល១គ.ម=១០០០ម៉ែត្រ) |
| ហ.ត | ហិចតា (គឺជាខ្នាតក្រឡាផ្ទៃដែល១ហ.ត=១០០០០ម៉ែត្រការ៉េ) |
| °C | អង្សាសេ (គឺជាខ្នាតសីតុណ្ហភាពមួយដែលគេកម្រិតពីភាពក្តៅ និងភាពត្រជាក់។ ឧទាហរណ៍ ទឹកពុះនៅកម្រិតសីតុណ្ហភាព ១០០°C ហើយកកនៅកម្រិត០°C )។ |
| mg/l | មីលីក្រាមក្នុងមួយលីត្រ (គឺជាខ្នាតទម្ងន់ ធៀបទៅនឹងសូលុយស្យុងនៃទឹក ឧស្ម័ន ឬខ្យល់)។ |
| nm | ណាណូម៉ែត្រ (គឺជាខ្នាតអន្តរជាតិមួយ ដែល ១ ណាណូម៉ែត្រ=១០-៩ម៉ែត្រ)។ |
| ppm | ភាគលាន (១ppm=១/១០០០០០=0.០០០០០១=១x១០-6។ |
| W/m² | វ៉ាត់ក្នុងមួយម៉ែត្រការ៉េ |
| Kw/h | គីឡូវ៉ាត់ម៉ោង |

សៀវភៅនេះណែនាំស្តីពី គម្រោងអាកាសធាតុវៃឆ្លាតសម្រាប់សហគមន៍នេះ គឺជាធនធានមួយសម្រាប់អ្នកដែលកំពុងធ្វើ ការស្រាវជ្រាវទៅលើការការប្រែប្រួលអាកាសធាតុ។

សៀវភៅនេះ បង្ហាញនូវព័ត៌មានសំខាន់ៗ ដែលវាកើតឡើងដោយសារការប្រែប្រួលអាកាសធាតុ និងការបន្សាំខ្លួន ការកាត់បន្ថយនៃអាកាសធាតុ ហើយវាក៏បង្ហាញផងដែរអំពីផលប៉ះពាល់ គោលនយោបាយ និងក្របខណ្ឌការងារផ្លូវច្បាប់ និងយន្តការហិរញ្ញវត្ថុអាកាសធាតុ។

សៀវភៅណែនាំសម្រាប់អ្នកសម្របសម្រួល រួមបញ្ចូលនូវសកម្មភាពបែបអន្តរកម្មនិងការណែនាំសម្រាប់អ្នកសម្របសម្រួលក្នុងការបង្រៀនចំពោះប្រធានបទនីមួយៗ។

ពិភពលោកកំពុងប្រឈម នឹងការគំរាមកំហែងពីការប្រែប្រួលអាកាសធាតុ មិនថាតែសម្រាប់អ្នកក្រីក្រនោះទេ។

សៀវភៅនេះគឺត្រូវបានរៀងរៀងឡើងក្នុងសារតីសាមគ្គីភាពការសហការណ៍ និងមានគោលបំណងដើម្បីគាំទ្រដល់សហគមន៍ក្រីក្រក្លាយជា គម្រោងវៃឆ្លាតឆ្លើយតបនឹងអាកាសធាតុ និងការកាត់បន្ថយការប្រែប្រួលអាកាសធាតុជាមាគ៌ាឆ្ពោះទៅរកការអភិវឌ្ឍប្រកបដោយចិរកាល។

